ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ..០០៣..[illegible]./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី...១៩ ខែ[illegible] ឆ្នាំ២០១១

# សេចក្តីណែនាំ
# ស្តីពី
# ការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

យោងតាមមាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាលបានចេញអនុក្រឹតលេខ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២ អនក្រ បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹតលេខ២១៩ ដោយកំណត់ឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ឱ្យបានយ៉ាងយូរត្រឹមឆ្នាំទី២នៃអាណត្តិរបស់ខ្លួន។ ផ្អែកតាមស្មារតីនេះ រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ ត្រូវរៀបចំបង្កើតឱ្យមានក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល នៅរដ្ឋបាលនីមួយៗរបស់ខ្លួន។

ការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ គឺជាការរៀបចំឱ្យមានយន្តការដ៏សមស្របមួយ ដើម្បីធានាឱ្យដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រព្រឹត្តទៅ ដោយមានការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ជាមួយក្រុមប្រឹក្សាប្រភេទផ្សេងទៀត ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ព្រមទាំងជាមួយអង្គការសង្គមស៊ីវិល និងវិស័យឯកជន ស្របតាមស្មារតីនៃច្បាប់ និងអនុក្រឹត្យដែលបានកំណត់។

ដើម្បីជួយសម្រួលដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំអំពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

## *១. អំពីការរៀបចំសមាសភាពក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ*

ក). **ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី** មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - អភិបាលរាជធានី | ប្រធាន |
| - អភិបាលរងរាជធានី០១រូប | អនុប្រធាន |
| - នាយករដ្ឋបាលសាលារាជធានី | សមាជិក |
| - ប្រធានមន្ទីរផែនការរាជធានី | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី | សមាជិក |
| - នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សារាជធានី | សមាជិក |
| - ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | សមាជិក |
| - ប្រធាន ឬតំណាងមន្ទីរ និងអង្គភាពជំនាញនានានៅរាជធានី | សមាជិក |
| - នាយក ឬតំណាងទីចាត់ការចំណុះសាលារាជធានី | សមាជិក |

ខ). **ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត** មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - អភិបាលខេត្ត | ប្រធាន |
| - អភិបាលរងខេត្ត០១រូប | អនុប្រធាន |
| - នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| - ប្រធានមន្ទីរផែនការខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| - នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សាខេត្ត | សមាជិក |
| - ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | សមាជិក |
| - ប្រធាន ឬតំណាងមន្ទីរ និងអង្គភាពជំនាញនានានៅខេត្ត | សមាជិក |
| - នាយក ឬតំណាងទីចាត់ការចំណុះសាលាខេត្ត | សមាជិក |

គ). **ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង** មានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - អភិបាលក្រុង | ប្រធាន |
| - អភិបាលរងក្រុង០១រូប | អនុប្រធាន |
| - នាយករដ្ឋបាលសាលាក្រុង | សមាជិក |
| - ប្រធានការិយាល័យផែនការ ស្ថិតិក្រុង | សមាជិកអចិន្ត្រៃយ៍ |
| - ប្រធានការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្រុង | សមាជិក |
| - ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាក្រុង | សមាជិក |
| - ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | សមាជិក |

- តំណាងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ សមាជិក
- ប្រធាន ឬតំណាងការិយាល័យ និងអង្គភាពជំនាញនានានៅក្រុង សមាជិក
- នាយក ឬតំណាងការិយាល័យចំណុះសាលាក្រុង សមាជិក

**ឃ). ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគស្រុក** មានសមាសភាពដូចខាងក្រោម ៖

- អភិបាលស្រុក ប្រធាន
- អភិបាលរងស្រុក០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលាស្រុក សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិស្រុក សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្រុក សមាជិក
- ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាស្រុក សមាជិក
- ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សមាជិក
- តំណាងការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ សមាជិក
- ប្រធាន ឬតំណាងការិយាល័យ និងអង្គភាពជំនាញនានានៅស្រុក សមាជិក
- នាយក ឬតំណាងការិយាល័យចំណុះសាលាស្រុក សមាជិក

**ង). ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខណ្ឌ** មានសមាសភាពដូចខាងក្រោម ៖

- អភិបាលខណ្ឌ ប្រធាន
- អភិបាលរងខណ្ឌ០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលាខណ្ឌ សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិខណ្ឌ សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុខណ្ឌ សមាជិក
- ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុសាលាខណ្ឌ សមាជិក
- ប្រធាន ឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សមាជិក
- តំណាងមកពីការិយាល័យគាំទ្រមូលដ្ឋានរបស់សាលារាជធានី សមាជិក
- ប្រធាន ឬតំណាងការិយាល័យ និងអង្គភាពជំនាញនានានៅខណ្ឌ សមាជិក
- នាយក ឬតំណាងការិយាល័យចំណុះសាលាខណ្ឌ សមាជិក

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវពិភាក្សាក្នុងគណៈអភិបាលរបស់ខ្លួនដើម្បីជ្រើសរើសអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ០១រូប សម្រាប់ស្នើជាអនុប្រធានក្រុមការងារខាងលើ។ បន្ទាប់ពីរៀបចំសមាសភាពនៃក្រុមការងារកសាងផែនការ ដូចដែលបានកំណត់ខាងលើរួចហើយ អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវយកបញ្ជី

សមាសភាពនេះទៅសុំការគាំទ្រជាមុនពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មុននឹងដាក់សុំយោបល់ណែនាំពីក្រុមប្រឹក្សារបស់ខ្លួន។

ក្រោយពីទទួលបានបញ្ជីសមាសភាពដែលស្នើឡើងដោយអភិបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា ដើម្បីពិភាក្សា និងផ្តល់យោបល់លើបញ្ជីសមាសភាពនោះ។ បន្ទាប់ពីទទួលបានការឯកភាពពីក្រុមប្រឹក្សា អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវចេញសេចក្តីសម្រេចបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។ សេចក្តីសម្រេចនេះត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ឬអភិបាលខេត្ត ឬអភិបាលក្រុង ឬអភិបាលស្រុក ឬអភិបាលខណ្ឌ ទៅតាមសមត្ថកិច្ចរៀងៗខ្លួន។

## ២. អំពីតួនាទី ភារកិច្ចរបស់ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បូកសរុបបញ្ហា និងតម្រូវការនានាដែលស្នើឡើងដោយក្រុង ស្រុក ខណ្ឌ និងដែលស្នើឡើងដោយមន្ទីរ អង្គភាពនានា ព្រមទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំឯកសារពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- កែសម្រួល និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ៣. *អំពីការអនុម័ត និងការផ្តល់អនុលោមភាព*

### ៣.១. ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវចាត់វិធានការដើម្បីរៀបចំប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ដោយត្រូវធានាថា **សេចក្តីព្រាងផែនការអភិវឌ្ឍន៍របស់ខ្លួន ត្រូវបានអនុម័តដោយក្រុមប្រឹក្សា និងត្រូវបញ្ជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងអំឡុងសប្តាហ៍ទី១ នៃខែមេសា ឆ្នាំ២០១១** និងត្រូវធានាថា **ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់ដោយក្រុមប្រឹក្សា នៅក្នុងអំឡុងឆ្នាំទី២ នៃអាណត្តិរបស់ខ្លួន** ពោលគឺ**មុនថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១១**។

លេខាធិការដ្ឋាន គ.ជ.អ.ប ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នពាក់ព័ន្ធនានា ត្រូវធ្វើការសម្របសម្រួល ពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត មុននឹងដាក់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពិនិត្យ និងផ្តល់អនុលោមភាព។ ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ (គិតចាប់ពីថ្ងៃដែលទទួលបាន ការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត) បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្ញើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តដែលបានផ្ញើមក ត្រូវចាត់ទុកថា ទទួលបានអនុលោមភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

នៅក្នុងដំណើរការពិនិត្យ និងផ្តល់អនុលោមភាព ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃ អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃ ត្រូវរាយការណ៍ និងស្នើសុំ គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្រោយពីទទួលបានការឆ្លើយតបពីក្រសួងមហាផ្ទៃ ក្នុងករណីពុំមានការណែនាំឲ្យកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្ត ពីក្រសួងមហាផ្ទៃទេ អភិបាលរាជធានី អភិបាលខេត្ត ត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ជាបន្ទាន់។ ដោយឡែក ក្នុងករណីមានការណែនាំឲ្យកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍របស់រាជធានី ខេត្តពីក្រសួងមហាផ្ទៃ អភិបាលរាជធានី ខេត្ត ត្រូវណែនាំក្រុមការងារកសាងផែនការ ឲ្យធ្វើការកែសម្រួលតាមការណែនាំទាំងនោះភ្លាម រួចដាក់ជូនក្រុមប្រឹក្សារាជធានី ខេត្ត ពិនិត្យ និងអនុម័តជាថ្មី ដោយផ្តោតលើចំណុចដែលបានកែសម្រួលទាំងនោះ។ បន្ទាប់ពីទទួលបានការ

ពិនិត្យ និងអនុម័តពីក្រុមប្រឹក្សា អភិបាលរាជធានី អភិបាលខេត្ត ត្រូវរៀបចំសេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការ អភិវឌ្ឍន៍រាជធានី ខេត្ត ជាបន្ទាន់។

សេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ត្រូវដាក់ជូនប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ចុះហត្ថលេខា។

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវតម្កល់ទុកជាឯកសារ មួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត និងត្រូវផ្ញើទៅក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធដទៃទៀត។

## ៣.២. ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវចាត់វិធានការដើម្បីរៀបចំប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគក្រុង ស្រុក ខណ្ឌ ដោយត្រូវធានាថា **សេចក្ដីព្រាងផែនការអភិវឌ្ឍន៍របស់ខ្លួន ត្រូវបានអនុម័តដោយក្រុមប្រឹក្សា និងត្រូវបញ្ជូនមកអភិបាលរាជធានី ខេត្ត ឲ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១១** និងត្រូវធានាថា **ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់ដោយក្រុមប្រឹក្សា នៅក្នុងអំឡុងឆ្នាំទី២ នៃអាណត្តិរបស់ខ្លួន** ពោលគឺ **មុនថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១១។**

អភិបាលរាជធានី ខេត្ត ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា ត្រូវធ្វើការពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌដែលបានផ្ញើមក។ ក្នុងរយៈពេលយ៉ាងយូរ ៣០ថ្ងៃ (គិតចាប់ពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្ដល់យោបល់របស់អភិបាលក្រុង ស្រុក ខណ្ឌ) បើគ្មានការឆ្លើយតបជាលាយល័ក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទេនោះ សេចក្ដីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ដែលបានផ្ញើមក ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

នៅក្នុងដំណើរការពិនិត្យ និងផ្ដល់អនុលោមភាព ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវរាយការណ៍ និងស្នើសុំមក លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្រោយពីទទួលបានការឆ្លើយតបពីអភិបាលរាជធានី ខេត្ត ក្នុងករណីពុំមានការណែនាំឲ្យកែសម្រួលលើខ្លឹមសារនៃសេចក្ដីព្រាងផែនការអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ ពីអភិបាលរាជធានី ខេត្តទេ អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវរៀបចំសេចក្ដីសម្រេចស្ដីពីការដាក់ឱ្យប្រើ

ប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ របស់ខ្លួនជាបន្ទាន់។ ដោយឡែកក្នុងករណីមានការណែនាំឲ្យកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍របស់ក្រុង ស្រុក ខណ្ឌ ពីអភិបាលរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវណែនាំក្រុមការងារកសាងផែនការ ឲ្យធ្វើការកែសម្រួលតាមការណែនាំទាំងនោះភ្លាម រួចដាក់ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ពិនិត្យ និងអនុម័តជាថ្មី ដោយផ្តោតលើចំណុចដែលបានកែសម្រួលទាំងនោះ។ បន្ទាប់ពីទទួលបានការពិនិត្យ និងអនុម័តពីក្រុមប្រឹក្សា អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវរៀបចំសេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ជាបន្ទាន់។

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ ត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខា។

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកជាឯកសារ មួយច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌ មួយច្បាប់នៅការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងត្រូវផ្ញើទៅអ្នកពាក់ព័ន្ធដទៃទៀត។

ទទួលបានសេចក្តីណែនាំនេះ អភិបាលរាជធានី អភិបាលខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ និង មន្ទីរ អង្គភាព ការិយាល័យពាក់ព័ន្ធត្រូវចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**សក់_សេដ្ឋា**

*ចម្លងជូន:*

- គ្រប់ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប
  "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ